01575093

**Declassified to Public**
**25 January 2019**

ORIGINAL DOCUMENT/DOCUMENT ORIGINAL
ថ្ងៃ ខែ ឆ្នាំ ទទួល (Date of receipt/Date de reception): 27 / 06 / 2018
ម៉ោង (Time/Heure): 15:30
មន្ត្រីទទួលបន្ទុកសំណុំរឿង/Case File Officer/L'agent chargé du dossier: SANN RADA



ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ
Kingdom of Cambodia
Nation Religion King
Royaume du Cambodge
Nation Religion Roi

អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា
Extraordinary Chambers in the Courts of Cambodia
Chambres Extraordinaires au sein des Tribunaux Cambodgiens

---

ថ្ងៃទី ២៧ ខែ មិថុនា ឆ្នាំ ២០១៨

**ជូនចំពោះ៖** **ប្រធានគណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា**

**ពី៖** **ចៅក្រម និល ណុន ប្រធានអង្គជំនុំជម្រះសាលាដំបូង**

**ចម្លងជូន៖** **លោក/លោកស្រីចៅក្រម និងមន្ត្រីច្បាប់ជាន់ខ្ពស់នៃអង្គជំនុំជម្រះសាលាដំបូង**
**លោក Victor Koppe សហមេធាវីអន្តរជាតិការពារក្តី នួន ជា**
**ភាគីទាំងអស់ក្នុងសំណុំរឿង ០០២**
**លោក Isaac Endeley ប្រធានអង្គភាពគាំពារការការពារក្តី**

**កម្មវត្ថុ៖** **ការបញ្ជាក់អំពីការបានទទួលលិខិតឆ្លើយតបរបស់គណៈមេធាវីនៃព្រះរាជា-ណាចក្រកម្ពុជា ចុះថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០១៨**

១. អង្គជំនុំជម្រះសាលាដំបូងសូមបញ្ជាក់ពីការបានទទួលលិខិតឆ្លើយតបរបស់គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ចុះថ្ងៃទី ២១ ខែ មិថុនា ឆ្នាំ ២០១៨ ដែលបានឆ្លើយតបទៅនឹងអនុស្សរណៈរបស់អង្គជំនុំជម្រះ ចុះថ្ងៃទី ៣១ ខែ ឧសភា ឆ្នាំ ២០១៨ (ឯកសារ E378/8/4) មានចំណងជើងថា "អំពីឋានៈរបស់សហមេធាវីអន្តរជាតិការពារក្តី នួន ជា ក្នុងសំណុំរឿង ០០២/០២"។

២. អង្គជំនុំជម្រះសូមជូនដំណឹងដល់គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាមេត្តាជ្រាបថា កាលពីថ្ងៃទី ២៦ ខែ មិថុនា ឆ្នាំ ២០១៨ អង្គជំនុំជម្រះបានបញ្ជូនលិខិតឆ្លើយតបរបស់គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជាទៅប្រធានអង្គភាពគាំពារការការពារក្តី (អ.គ.ក.) លោក Isaac Endeley និងលោក Victor Koppe រួចហើយ បន្ទាប់ពីទទួលបានលិខិតបកប្រែជាភាសាអង់គ្លេស។ អង្គជំនុំជម្រះបានស្នើឲ្យលោក Koppe អនុវត្តដោយផ្ទាល់ទៅតាមសំណើរបស់គណៈមេធាវីនៃព្រះរាជាណាចក្រកម្ពុជា ដែលមានរៀបរាប់លម្អិតក្នុងលិខិតឆ្លើយរបស់គណៈមេធាវីនៅសន្លឹកទី ៣ ពាក់ព័ន្ធនឹង "ព័ត៌មាន និងឯកសារជាក់លាក់ ទាក់ទងនឹងឋានៈរបស់គាត់ជាមួយគណៈមេធាវីបរទេស" ត្រឹមថ្ងៃទី ២៨ ខែ មិថុនា ឆ្នាំ ២០១៨។